ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible]........សហវ.[illegible]

# ប្រកាស
## ស្តីពី
## ការបែងចែកភារកិច្ចថ្នាក់ដឹកនាំអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/៩៩ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩៩៩ អនក្រ.តត ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ស្តីពីការតែងតាំងមន្ត្រីរាជការ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ ... ភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥ ២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.** -

ប្រគល់ភារកិច្ចជូន ឯកឧត្តម បណ្ឌិត ប៉ែន ស៊ីម៉ន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា ឲ្យទទួលបន្ទុកដឹកនាំគ្រប់គ្រងការងាររបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាទាំងមូលជារួម និងទទួលដឹកនាំដោយផ្ទាល់លើនាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង និងនាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស ព្រមទាំងទទួលបន្ទុកការងារផ្សេងទៀតពាក់ព័ន្ធនឹងការអភិវឌ្ឍន៍វិស័យឯកជននិងកិច្ចសម្រួលពាណិជ្ជកម្ម ។

**ប្រការ ២.** -

ប្រគល់ភារកិច្ចជូនលោកអគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដូចតទៅ ៖

១. លោក **ឡាយ ឫទ្ធី** អគ្គនាយករង ជាជំនួយការឲ្យអគ្គនាយកលើការងារនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ សាខាគយនិងរដ្ឋាករនាំចេញ សាខាគយនិងរដ្ឋាករខេត្តកំពង់ចាម សាខាគយនិងរដ្ឋាករខេត្តក្រចេះ សាខាគយនិងរដ្ឋាករខេត្តស្ទឹងត្រែង សាខាគយនិងរដ្ឋាករខេត្តរតនគិរី និងសាខាគយនិងរដ្ឋាករខេត្តមណ្ឌលគិរី ព្រមទាំងទទួលបន្ទុកការងារផ្សេងទៀតពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ធនធានមនុស្ស ។

២. លោក **ឯម មិនថវ:** អគ្គនាយករង ជាជំនួយការឲ្យអគ្គនាយកលើការងារនាយកដ្ឋានរដ្ឋាករ សាខាគយនិងរដ្ឋាករផែស្ងួត សាខាគយនិងរដ្ឋាករខេត្តបាត់ដំបង សាខាគយនិងរដ្ឋាករខេត្តបន្ទាយមានជ័យ សាខាគយនិងរដ្ឋាករខេត្តសៀមរាប សាខាគយនិងរដ្ឋាករខេត្តឧត្តរមានជ័យ សាខាគយនិងរដ្ឋាករខេត្តប៉ៃលិន និង សាខាគយនិងរដ្ឋាករខេត្តព្រះវិហារ ព្រមទាំងទទួលបន្ទុកការងារផ្សេងទៀតពាក់ព័ន្ធនឹងកម្មវិធីរបស់ភ្នាក់ងារផ្តល់ជំនួយពហុភាគី (ធនាគារពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ ...) ។

៣. លោក **គុណ ញឹម** អគ្គនាយករង ជាជំនួយការឲ្យអគ្គនាយកលើការងារនាយកដ្ឋានរបបគយ សាខាគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ សាខាគយនិងរដ្ឋាករកំពង់ផែអន្តរជាតិភ្នំពេញ សាខាគយនិងរដ្ឋាករខេត្តកណ្តាល សាខាគយនិងរដ្ឋាករខេត្តព្រៃវែង និងសាខាគយនិងរដ្ឋាករខេត្តកំពង់ឆ្នាំង ព្រមទាំងទទួលបន្ទុកការងារផ្សេងទៀតពាក់ព័ន្ធនឹងអង្គការពាណិជ្ជកម្មពិភពលោក អង្គការគយពិភពលោក និងការអនុវត្តកម្មវិធីកំណែទម្រង់និងទំនើបកម្មរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។

៤. លោក **ម៉ែន សំអាត** អគ្គនាយករង ជាជំនួយការឲ្យអគ្គនាយកលើការងារនាយកដ្ឋានកិច្ចការច្បាប់ សវនកម្មនិងទំនាក់ទំនងសាធារណៈ លេខាធិការដ្ឋាន សាខាគយនិងរដ្ឋាកររាជធានីភ្នំពេញ សាខាគយនិងរដ្ឋាករខេត្តព្រះសីហនុ សាខាគយនិងរដ្ឋាករខេត្តស្វាយរៀង សាខាគយនិងរដ្ឋាករខេត្តពោធិ៍សាត់ និងសាខាគយនិងរដ្ឋាករខេត្តកំពង់ធំ ព្រមទាំងទទួលបន្ទុកយន្តការភាពជាដៃគូគយ-ផ្នែកឯកជន យន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ យន្តការសវនកម្មផ្ទៃក្នុង និងការងារគ្រប់គ្រងហានិភ័យគយ ។

៩. លោក **នួន ចំនួនរិទ្ធ** អគ្គនាយករង ជាជំនួយការឲ្យអគ្គនាយកលើការងារនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ សាខាគយនិងរដ្ឋាករប្រៃសណីយ៍ សាខាគយនិងរដ្ឋាករ កំពង់ផែអន្តរជាតិក្រុងព្រះសីហនុ សាខាគយនិងរដ្ឋាករខេត្តកោះកុង សាខាគយនិងរដ្ឋាករ ខេត្តកំពត សាខាគយនិងរដ្ឋាករខេត្តកែប សាខាគយនិងរដ្ឋាករខេត្តកំពង់ស្ពឺ និងសាខាគយ និងរដ្ឋាករខេត្តតាកែវ ព្រមទាំងទទួលបន្ទុកការងារផ្សេងទៀតពាក់ព័ន្ធកិច្ចការអន្តរជាតិ ជាពិសេស ការងារអាស៊ាន មហាអនុតំបន់មេគង្គ និងការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនានា ។

**ប្រការ ៣.** -

អគ្គនាយករងទាំងអស់ មុននឹងសម្រេចតាមភារកិច្ចទទួលខុសត្រូវដូចមានចែងក្នុងប្រការ ២ ក្នុង នាមអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវរាយការណ៍និងសុំយោបល់សម្រេចពីប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជាជាមុនសិន ។ ក្នុងករណីដែលប្រតិភូរាជរដ្ឋាភិបាលទទួល បន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជាពិនិត្យឃើញថា កិច្ចការដែលអគ្គនាយករងលើកឡើងមាន លក្ខណៈស្មុគស្មាញនិងមានទំហំធំ ត្រូវរាយការណ៍ និងសុំការសម្រេចពីឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ ៤.** -

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា ត្រូវចាត់ចែងណែនាំបន្ថែម ឲ្យបានច្បាស់លាស់អំពីនីតិវិធី និងរបៀបរបបបំពេញការងារប្រចាំថ្ងៃ ជាពិសេសពាក់ព័ន្ធនឹងទម្រង់ និង បែបបទនៃការសុំការសម្រេច របបប្រជុំ និងទំនាក់ទំនងការងារផ្ទៃក្នុង ។

**ប្រការ ៥.** -

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គនាយក ប្រធាននាយកដ្ឋានរដ្ឋបាលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អង្គភាពពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាម ភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០១៣

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ